ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខ ២១
ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២
សំណុំរឿងជំនុំជម្រះលេខ ២២៣
ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២
**សាលក្រមព្រហ្មទណ្ឌ**
**លេខ: ៣២ "ច"/២៩៣**
ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

-បានបើកសវនាការជាសាធារណៈ នៅសាលសវនាការលេខ ក១ នៃសាលាដំបូងខេត្តសៀមរាប ។

-កាលបរិច្ឆេទបើកសវនាការ ៖ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ វេលាព្រឹក។

-កាលបរិច្ឆេទប្រកាសសាលក្រម ៖ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ វេលាព្រឹក ។

**សមាសភាពចូលរួមសវនាការមាន៖**

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ឋានៈ ប្រធានក្រុមប្រឹក្សា
លោក ឋានៈ ចៅក្រមប្រឹក្សា
លោកស្រី ឋានៈ ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

ឯកឧត្តម [redacted] ឋានៈ ព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ឋានៈ ក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២១ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] ប្រុសតូច ភេទប្រុស កើតនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៧ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិ [redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី៣ មុខរបរមិនពិតប្រាកដ នៅលីវ ឪពុកឈ្មោះ [redacted] ទុង "រស់" ម្តាយឈ្មោះ [redacted] រយ៉េន "រស់" ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៦ ឃខ/៣ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២ ។

-ដីកាបង្គាប់ឲ្យដោះលែងលេខ ២៦៧/២០២២ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។

-លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។



Scanned with CamScanner

២.ឈ្មោះ [redacted] សេរី ភេទប្រុស កើតនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៧ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិ [redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី៤ មុខរបរ ជាងជួសជុលរថយន្ត នៅលីវ ឪពុកឈ្មោះ [redacted] វណ្ណៈ "រស់" ម្តាយឈ្មោះ [redacted] ចំរើន "រស់" ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៥ ឃខ/៣ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២ ។

-ដីកាបង្គាប់ឲ្យដោះលែងលេខ ២៦៦/២០២២ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។

៣.ឈ្មោះ [redacted] អារុន ភេទប្រុស កើតនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០០៧ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិ [redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី១ នៅលីវ ឪពុកឈ្មោះ [redacted] សុភ័ណ្ឌ "រស់" ម្តាយឈ្មោះ [redacted] យ៉ូន "រស់" ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៦ ឃខ/៣ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២ ។

-ដីកាបង្គាប់ឲ្យដោះលែងលេខ ២៦៨/២០២២ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។

ជាប់ចោទពីបទ លួច ប្រព្រឹត្តនៅភូមិតាចេក សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី៥ ខែមករា ឆ្នាំ២០២២ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

## ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី

ឈ្មោះ [redacted] វិចិត្រ ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប អត្តសញ្ញាណប័ណ្ណលេខ 180292027 ។

-ពាក្យសុំដកពាក្យបណ្តឹង ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ។

## អង្គហេតុកើតឡើងមានដូចតទៅ៖

កាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ វេលាម៉ោង១១ និង៤០នាទីព្រឹក នៅចំណុចដីឡូត៍មួយកន្លែងដោយមានរបងធ្វើពីឥដ្ឋព័ទ្ធជុំវិញ ស្ថិតនៅភូមិតាចេក សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ឈ្មោះ [redacted] សេរី ភេទប្រុស កើតនៅឆ្នាំ២០០៧, ឈ្មោះ [redacted] ប្រុសតូច ភេទប្រុស កើតនៅឆ្នាំ២០០៧, ឈ្មោះ [redacted] អារុន ភេទប្រុស កើតនៅឆ្នាំ២០០៧ និងឈ្មោះ [redacted] ពិសិទ្ធ ភេទប្រុស កើតនៅឆ្នាំ២០០៨ បានធ្វើសកម្មភាពចូលទៅក្នុងដីឡូត៍ដែលមានទីតាំងដូចខាងលើ ហើយបានលួចយកដែកបំពង់ទីបមូលប្រវែង ៣ម៉ែត្រ ចំនួន៣, ដែកបំពង់ទីបមូលប្រវែង ១,៥ម៉ែត្រ ចំនួន ៥, ដែកបំពង់ទីបជ្រុងប្រវែង ២ម៉ែត្រ ចំនួន១, ក្រចាប់ដែក ចំនួន១២ និងសម្ភារៈមួយចំនួនទៀត ជារបស់ឈ្មោះ [redacted] វិចិត្រ ភេទប្រុស អាយុ ៣៤ឆ្នាំ ដែលបានទុកក្នុងដីឡូត៍របស់ខ្លួន។ ក្រោយពីឈ្មោះ [redacted] វិចិត្រ បានទទួលព័ត៌មានពីប្រពន្ធរបស់ខ្លួនរួចមក ឈ្មោះ [redacted] វិចិត្រ បានដាក់ពាក្យបណ្តឹងទៅប៉ុស្តិ៍នគរបាលរដ្ឋបាលជ្រាវ ក្រោយមកកម្លាំងសមត្ថកិច្ចបានធ្វើការឃាត់ខ្លួន និងសួរចម្លើយលើឈ្មោះ [redacted] ប្រុសតូច , ឈ្មោះ [redacted] សេរី , ឈ្មោះ [redacted] អារុន និងឈ្មោះ [redacted] ពិសិទ្ធ បានឆ្លើយសារភាពថា ពួកគេពិតជាបានធ្វើសកម្មភាពលួចសម្ភារៈដែក



Scanned with CamScanner

ប៉ព្ធង់ទីប និងរបស់របរនៅចំណុចដីឡូតិ៍មួយកន្លែង ដោយមានរបងថ្មធ្វើអំពីឥដ្ឋព័ទ្ធជុំវិញ ស្ថិតនៅភូមិតាចេក សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ពិតមែន។

បានឃើញ របាយការណ៍សំយោគលេខ ០០៤/០២២ នប.ក្រសរ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលក្រុងសៀមរាប នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១៦៧ អ.យ.ច/២២ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប ។

បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១២៤៦ ពស.ព្រស/៣ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តសៀមរាប។

បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាចៅក្រមជំនុំជម្រះលេខ ២៤៤ ពស.ព្រជ(ក) ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ប្រុសតូច បានឆ្លើយថា កាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ ឈ្មោះ [redacted] និងឈ្មោះ អារុន បានទៅយកខ្លួននៅផ្ទះដើរលេងនៅភ្នំក្រោម ដើរលេងរហូតដល់ម៉ោង ៩ព្រឹក ចុះពីភ្នំក្រោមមកវិញនាំគ្នាទៅលួចដែកនៅដីឡូតិ៍ ដោយខ្លួនលូនតាមប្រហោងរបង ចំណែកពីនាក់ទៀតឡើងលើរបង។ ពេលចូលទៅដល់ពួលខ្លួនធ្វើសកម្មភាពលួចយកដែកជ្រុង ដែកមូលប្រហែល ៣០ដើម ដែកដាប់ ១០ដើម ពូថៅមួយ និងចង្រ្កានហ្គាសមួយ រួចក៏នាំគ្នាយកចេញពីដីឡូតិ៍នោះចង្រ្កានបោះផ្លោះរបង ដែកយកតាមប្រហោងរបង ពេលខ្លួនចេញមកឃើញសមត្ថកិច្ចនៅមុខដីឡូតិ៍នោះតែម្តង និងឃាត់ខ្លួនពួកខ្លួនភ្លាមៗ ។ ពួកខ្លួនទាំងបីនាក់ធ្លាប់លួចដែកពីរលើក លួចលើកទីមួយលក់បានប្រាក់ ៦០.០០០ (ប្រាំមួយម៉ឺនរៀល) លើកទីពីរយកដែកចេញពីដីឡូតិ៍ត្រូវសមត្ថកិច្ចចាប់តែម្តង ។ ខ្លួនមានមុខរបរជាងផ្សារដែក បានប្រាក់ឈ្នួលមួយថ្ងៃពីរម៉ឺន ឬបីម៉ឺន ។ ដីឡូតិ៍ខ្លួនចូលលួចនៅក្បែរផ្ទះខ្លួន ដីទំនេរមានតែរោង ឃើញគេទុកដែកចោល ។ ខ្លួនសន្យាឈប់លួចទៀតហើយ ។

-ជនជាប់ចោទឈ្មោះ [redacted] សេរី បានឆ្លើយថា ចម្លើយឈ្មោះ ប្រុសតូច ពិតជាត្រឹមត្រូវ ។ ពួកខ្លួនពិតជាបានធ្វើសកម្មភាពលួចដែកពីរដងមែន លួចលើកទីមួយលក់បានប្រាក់ប្រាំមួយម៉ឺនរៀលចែកប្រាក់គ្នាស្មើ លួចលើកទីពីរពុំទាន់បានលក់ទេត្រូវសមត្ថកិច្ចឃាត់ខ្លួន ។ ពេលធ្វើសកម្មភាពលួចនោះខ្លួន និងឈ្មោះ សេរី ប្រមូលដែក ចំណែកឈ្មោះ ប្រុសតូច យកពូថៅ និងចង្រ្កានហ្គាល ។ ពេលលួចបាននាំគ្នាដឹកជញ្ជូនចេញពីដីឡូតិ៍ក៏ត្រូវសមត្ថកិច្ចជិះម៉ូតូល្បាតឃើញឃាត់ខ្លួនតែម្តង ។ ខ្លួនសន្យាឈប់លួចទៀតហើយ ។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] អារុន នៅដំណាក់កាលចៅក្រមស៊ើបសួរថា កាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ វេលាម៉ោង៧ ព្រឹក ឈ្មោះ [redacted] សេរី បានជិះម៉ូតូទៅយកខ្លួននៅផ្ទះរបស់ខ្លួន ដោយបានប្រាប់ខ្លួនថា ទៅទារលុយពីឈ្មោះ អាតូច ពេលនោះខ្លួនបានជិះម៉ូតូជាមួយឈ្មោះ [redacted] សេរី ដោយឈ្មោះ [redacted] សេរី ជាអ្នកឌុបខ្លួនចេញពីផ្ទះទៅកន្លែងដែលមានទុកដែកមួយកន្លែង ហើយបន្ទាប់មកឈ្មោះ [redacted] សេរី បានផ្លោះចូលទៅក្នុងរបងហើយលួចយកដែក បានចំនួន ៣ដើម ហើយបានបោះឱ្យខ្លួននៅក្រៅរបង រួចហើយនាំគ្នាយកដែកចេញពីកន្លែងនោះយកទៅលក់នៅកន្លែងអេតចាយមួយកន្លែងស្ថិតនៅភូមិបុស្សក្រឡាញ់ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ដោយលក់

បានប្រាក់ចំនួន ១៥,០០០(មួយម៉ឺនប្រាំពាន់)រៀល រួចក៏បានជិះម៉ូតូទៅផ្ទះឈ្មោះ អាតូច ដើម្បីទៅលេងភ្នំក្រោម ពេលនោះពួកខ្លួនបានជិះម៉ូតូមួយគ្រឿងមានគ្នា ០៣នាក់ នៅពេលដែលខ្លួនទៅដល់ភ្នំក្រោមបានប្រហែល២០ ទៅ៣០នាទី ពួកខ្លួនបានជិះម៉ូតូត្រឡប់មកវិញ ។ ដោយនៅពេលដែលពួកខ្លួនត្រឡប់មកវិញនោះ ពួកខ្លួនក៏បានជិះម៉ូតូទៅកន្លែងដែលពួកខ្លួនបានលួចដែកនោះម្តងទៀត នៅពេលដែលទៅដល់កន្លែងលួចដែកនោះ ឈ្មោះ [redacted] សេរី បានផ្តោះរបងចូលទៅមុន ហើយបោះដែកតាមទ្វារក្រោយឱ្យឈ្មោះ តូច នៅចាំខាងក្រៅបន្ទាប់មកពួកខ្លួនបានចេញពីក្នុងរបងនោះមកក្រៅដើម្បីប្រមូលដែកយកទៅលក់ ពេលនោះស្រាប់សមត្ថកិច្ចមកទាន់ បានឃាត់ខ្លួនពួកខ្លួនតែម្តង។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សេរី នៅដំណាក់កាលចៅក្រមស៊ើបសួរថា នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០២២ វេលាម៉ោង១៩ និង៣០នាទី ខ្លួនបានជិះម៉ូតូទៅលេងផ្ទះប្អូនស្រីជីដូនមួយខ្លួន ស្ថិតនៅភូមិបុស្សក្រឡាញ់ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប បានជិះម៉ូតូមួយគ្រឿងម៉ាក HONDA DREAM C125 ពណ៌ក្រហម ផ្លាកលេខ សៀមរាប 1B-0137 នៅពេលដែលខ្លួនទៅដល់ ខ្លួនបានអង្គុយលេង ស្រាប់តែពេលនោះខ្លួនបានឃើញឈ្មោះ [redacted] ប្រុសតូច ភេទប្រុស រស់នៅភូមិបុស្សក្រឡាញ់ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប បានជិះម៉ូតូរបស់គេមកផ្ទះប្អូនស្រីជីដូនមួយខ្លួនដែរ ពេលនោះឈ្មោះ [redacted] ប្រុសតូច បានបបួលខ្លួនទៅលួចដែក។ ពេលនោះពួកខ្លួនក៏បាននាំគ្នាជិះម៉ូតូរបស់ឈ្មោះ [redacted] ប្រុសតូច ទៅយកឈ្មោះ សិទ្ធិ ភេទប្រុស អាយុប្រហែល ១៤ឆ្នាំ ម្នាក់ទៀត ហើយជិះគ្នាបីនាក់ រួចទៅធ្វើសកម្មភាពលួចដែក នៅចំណុចដីឡូត៍មួយកន្លែង មានរបងថ្មព័ទ្ធជុំវិញ ស្ថិតនៅភូមិតាចេក សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប នៅពេលទៅដល់កន្លែងកើតហេតុពួកខ្លួនបានផ្តោះរបងចូលលួចយកដែកទីបមូល និងជ្រុងប្រវែងប្រហែល២ម៉ែត្រ ទៅ៤ម៉ែត្រ ចំនួន ១០ដើម រួចដាក់លើម៉ូតូយកទៅលក់នៅកន្លែងអេតចាយមួយកន្លែង ស្ថិតនៅភូមិបុស្សក្រឡាញ់ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប មានទម្ងន់សរុបចំនួន ៤៥គីឡូក្រាម លក់បានប្រាក់ ចំនួន ៦៥,៥០០(ប្រាំមួយម៉ឺនប្រាំពាន់ប្រាំរយ)រៀល ហើយបានចែកប្រាក់គ្នាម្នាក់ៗ ចំនួន ២០,០០០(ពីរម៉ឺន)រៀល រួចក៏បានត្រឡប់ទៅផ្ទះរៀងៗខ្លួនទៅ។ បន្ទាប់មកនៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ វេលាម៉ោងប្រហែល៩ ខ្លួនបានជិះម៉ូតូរបស់ខ្លួនខាងលើ ជាមួយឈ្មោះ [redacted] អារុន ភេទប្រុស ទៅធ្វើសកម្មភាពលួចដែក នៅចំណុចទីតាំងដដែលខាងលើនេះដោយលួចបានដែកចំនួន ៣ដើម ទម្ងន់ ១៥(ដប់ប្រាំ)គីឡូក្រាម ហើយយកទៅលក់បានប្រាក់ចំនួន១៥,០០០(មួយម៉ឺនប្រាំពាន់)រៀល ហើយបានចែកគ្នាជាមួយឈ្មោះ [redacted] អារុន រួចក៏បាននាំគ្នាទៅអង្គុយលេងនៅផ្ទះប្អូនស្រីជីដូនមួយខ្លួន នៅភូមិបុស្សក្រឡាញ់ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ស្រាប់តែឃើញឈ្មោះ ទុង ប្រុសតូច ដើរមកដល់ហើយបានបបួលខ្លួនទៅលួចដែកម្តងទៀត ពេលនោះខ្លួនក៏បានជិះម៉ូតូរបស់ខ្លួនដោយពេលនោះមានខ្លួន ឈ្មោះ [redacted] ប្រុសតូច និងឈ្មោះ [redacted] អារុន ដល់ចំណុចទីតាំងកើតហេតុនៅភូមិតាចេក សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ពួកខ្លួនបានធ្វើសកម្មភាពលួចយកដែក ខណៈពេលនោះដែរក៏ស្រាប់កម្លាំងសមត្ថកិច្ចមកដល់បានធ្វើការឃាត់ខ្លួន ពួកខ្លួនតែម្តង។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ប្រុសតូច នៅដំណាក់កាលចៅក្រមស៊ើបសួរថា កាលពីថ្ងៃទី៥ ខែមករា ឆ្នាំ២០២២ វេលាម៉ោងប្រហែល១០ព្រឹក មានមិត្តភក្តិប្រុសខ្លួន ចំនួនពីរនាក់បានជិះម៉ូតូមួយគ្រឿង ម៉ាក HONDA DREAM ស៊េរីឆ្នាំ២០០២ ពណ៌ក្រហម ទៅផ្ទះរបស់ខ្លួន ហើយពួកបានបបួល

ខ្លួនទៅដើរលេងនៅភ្នំក្រោម ហើយពួកខ្លួនក៏បានទៅលេងនៅលើភ្នំក្រោមបានប្រហែល ៣០នាទី ក្រោយមកពួកខ្លួនក៏បាននាំគ្នាត្រឡប់មកវិញ។ នៅពេលដែលពួកខ្លួនត្រឡប់មកវិញខ្លួនជាអ្នកឌុប លុះដល់ចំណុចដីឡូតិ៍មួយកន្លែង ស្ថិតនៅភូមិតាចេក សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ឈ្មោះ [redacted] សេរី បានប្រាប់ថា មានគេទុកដែកចោលនៅដីឡូតិ៍ ពេលនោះពួកខ្លួនបាននាំគ្នាទៅលួចយកដែកនោះ យកទៅលក់ នៅពេលដែលពួកខ្លួនទៅលួចដែកនោះ ឈ្មោះ [redacted] សេរី ជាអ្នកឡើងរបងចូលទៅលួចមុនគេ បន្ទាប់មកឈ្មោះ [redacted] អារុន និងខ្លួនឡើងរបងចូលតាមក្រោយ។ បន្ទាប់ពីពួកខ្លួនចូលទៅលួចដែកនោះបានហើយពួកខ្លួនបានបោះដែកនោះមកខាងក្រៅរបង ហើយបានប្រមូលចងបម្រុងយកទៅលក់ ស្រាប់តែសមត្ថកិច្ចមកទាន់បានធ្វើការឃាត់ខ្លួនពួកខ្លួនតែម្តង។

-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វិចិត្រ នៅដំណាក់កាលចៅក្រមស៊ើបសួរថា ខ្លួនមានដីមួយកន្លែងស្ថិតនៅភូមិតាចេក សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប មានធ្វើរបងរៀបឥដ្ឋព័ទ្ធជុំវិញដី និងមានរោងមួយទំហំ ៤ម៉ែត្រ x ២ម៉ែត្រ ពុំមានជញ្ជាំងព័ទ្ធជុំវិញទេ មានតែជញ្ជាំងម្ខាងជាប់និងរបងដី និងមានសោទ្វាររបងចាក់ត្រឹមត្រូវសម្រាប់ដាក់សម្ភារៈ។ នៅក្នុងដីឡូតិ៍នោះមានដាក់សម្ភារៈគ្រឿងសំណង់មានដូចជា ដែកទីបមូល, ទីបជ្រុង និងសម្ភារៈផ្សេងៗមួយចំនួនទៀត ។ នៅពីថ្ងៃទី៥ ខែមករា ឆ្នាំ២០២២ វេលាម៉ោងប្រហែល១១ និង៤០នាទី ប្រពន្ធខ្លួនបានទូរស័ព្ទមកប្រាប់ខ្លួនថា មានចោរចូលលួចដែកនៅក្នុងដីឡូតិ៍ខាងលើនេះ ខ្លួនក៏បានជិះម៉ូតូទៅមើលឃើញ បាត់សម្ភារៈរួមមានដែកទីបជ្រុងចំនួន ៤(បួន)ដើម ក្នុងនោះមួយដើមប្រវែង ២,៥ម៉ែត្រ, ដែកទីបមូលទំហំ ៥សង់ទីម៉ែត្រ ប្រវែង ៣,៥ម៉ែត្រ ចំនួនប្រហែល ៣០(សាមសិប)ដើម, ក្រចាប់សម្រាប់ចាប់ដែកមូលប្រហែល ៥០(ហាសិប)គ្រាប់ និងចង្រ្កានហ្គាសចំនួន១(មួយ) ក្រៅពីនោះពុំមានបាត់បង់សម្ភារៈអ្វីផ្សេងទៀតទេ។ អ្នកដែលបានលួចសម្ភារៈសំណង់របស់ខ្លួននោះ ខ្លួនពុំដែលស្គាល់ឈ្មោះ និងស្គាល់មុខមាត់ទេ។ កន្លងមកពុំដែលមានចោរចូលលួចសម្ភារៈសំណង់ទាំងនោះទេ ទើបនៅថ្ងៃទី៥ ខែមករា ឆ្នាំ២០២២បាត់សម្ភារៈទាំងនោះ ។ បន្ទាប់ពីដឹងថាបាត់សម្ភារៈដូចបានរៀបរាប់ខាងលើរួចមក ខ្លួនក៏បានទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ជ្រាវ ក្រុងសៀមរាប។ ខ្លួនបានទទួលសម្ភារៈដែលចោរបានលួចនោះមកវិញខ្លះដែរ មានដូចជា ចង្ក្រានហ្គាស ចំនួន១(មួយ) ដែកទីបជ្រុង ចំនួន២(ពីរ)ដើម, ដែកទីបមូលចំនួន ៦(ប្រាំមួយ)ដើម, ដែកក្រចាប់ចំនួន ៨(ប្រាំបី)គ្រាប់, និងដែកដាប់មួយចំនួនទៀត។ ខ្លួនសូមសំណូមពរ ទៅតុលាការមិនទាមទារថ្លៃបាត់បង់សម្ភារៈដែលចោរបាលួច និងថ្លៃសំណងជំងឺចិត្តពីជនល្មើសទាំងទេ និងសូមឱ្យតុលាការផ្តន្ទាទោសទៅលើជនល្មើសតាមច្បាប់ ។

-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] មុំ នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា ខ្លួនមករស់នៅក្នុងភូមិសាស្ត្រសង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប នេះគឺបានរយៈពេល ០៥ឆ្នាំមកហើយ ដំបូងឡើយខ្លួនមករស់នៅក្នុងភូមិក្រសាំង សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ដោយខ្លួន និងប្តីបានមកស្នាក់នៅជាមួយម្តាយក្មេកខ្លួន ហើយប្តីរបស់ខ្លួនជាអ្នកដើរទិញអេតចាយ ចំណែកខ្លួននៅផ្ទះមើលកូននៅពេលដែលប្តីរបស់ខ្លួនទិញអេតចាយបាន ប្តីរបស់ខ្លួនតែងតែបានយកអេតចាយទៅលក់បន្តឱ្យចៅរ៉ែអេតចាយ ។ ទើបតែរយៈពេលពីរខែចុងក្រោយនេះ ខ្លួន និងប្តីខ្លួនបាននាំគ្នាទៅស្នាក់នៅផ្ទះជួលស្ថិតនៅភូមិតាចេក សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានម្ចាស់ផ្ទះឈ្មោះ គា ចាប់ពីពេលនោះមកប្តី



Scanned with CamScanner

របស់ខ្លួនបានដើរទិញអេតចាយផង និងទទួលទិញអេតចាយនៅផ្ទះផង ដោយខ្លួនជាអ្នកទទួលទិញអេតចាយនៅផ្ទះ ។ ជាក់ស្ដែងខ្លួនបានទិញអេតចាយ(ដែក) ពីក្មេងប្រុសម្នាក់ មានសក់ពណ៌ក្រហមបានយកមកលក់ឱ្យខ្លួនជាច្រើនលើកមកដែរ ដោយចន្លោះពី ៣ ទៅ ៤ថ្ងៃ ទើបយកអេតចាយមកលក់ឱ្យខ្លួនម្ដង ។ ខ្លួនទទួលទិញអេតចាយពីក្មេងប្រុសមិនស្គាល់ឈ្មោះនោះ ចុងក្រោយនៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០២២ បានចំនួន ១០(ដប់)គីឡូក្រាម ជាប្រភេទកំណាត់ដែកចម្រុះ (ដែកថ្នាំងអំពៅ និងដែកជ្រុង)។ នៅព្រឹកថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ មានក្មេងប្រុសមិនស្គាល់ឈ្មោះបានជិះម៉ូតូមិនចាំម៉ាក បានយកដែកបំពង់ទីបចំនួន ៣(បី)ដើម មកលក់ឱ្យខ្លួនតែពេលនោះខ្លួនមិនបានទទួលទិញ ហើយរូបគេក៏បានត្រឡប់ទៅវិញ ហើយខ្លួនក៏មិនដឹងថា រូបគេយកដែកនោះទៅលក់ឱ្យអ្នកណានោះទេ ហើយពេលនោះខ្លួនបានស្នាក់នៅផ្ទះរហូត លុះដល់វេលាម៉ោងប្រហែល ១៣ និង៣០នាទី ឃើញមានសមត្ថកិច្ចនាំក្មេងដែលមានសក់ពណ៌ក្រហម ដែលធ្លាប់យកដែកអេតចាយលក់ឱ្យខ្លួន ទៅចង្អុលបង្ហាញពីទីតាំងផ្ទះរបស់ខ្លួនថា រូបគេធ្លាប់យកដែកលក់ឱ្យខ្លួន បន្ទាប់ពីមានការចង្អុលបង្ហាញរួច ខ្លួននិងប្ដីត្រូវបានសមត្ថកិច្ចអញ្ជើញឱ្យទៅបំភ្លឺរឿងហេតុខាងលើនេះ នៅប៉ុស្ដិ៍នគរបាលរដ្ឋបាលជ្រាវតែម្ដង។

## សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានបញ្ចប់ការសួរចេញដោល និងពិនិត្យភស្តុតាងរួចមកឃើញថា ឈ្មោះ [redacted] ប្រុសតូច ឈ្មោះ [redacted] សេរី និងឈ្មោះ [redacted] អារុន ត្រូវបានបញ្ជូនមកជំនុំជម្រះពីបទៈ លួច ប្រព្រឹត្តនៅភូមិតាចេក សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី៥ ខែមករា ឆ្នាំ២០២២ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។ នាពេលសវនាការឈ្មោះ [redacted] ប្រុសតូច និងឈ្មោះ [redacted] សេរី បានឆ្លើយសារភាពមានភាពស៊ីសង្វាក់គ្នាថា ពួកខ្លួនមានគ្នាបីនាក់បានធ្វើសកម្មភាពខ្លះលូនតាមរបង ខ្លះផ្លោះរបងចូលដីឡូត៍មួយកន្លែងដែលពុំមានមនុស្សនៅរួចធ្វើសកម្មភាពលួចដែក ពូថៅ ចង្ក្រានហ្គាស យកចេញពីដីឡូត៍ក៏ជួបសមត្ថកិច្ចឃាត់ខ្លួនតែម្ដង ។ ចម្លើយសារភាពជនជាប់ចោទទាំងពីរនាក់នេះមានភាពស៊ីសង្វាក់ផងដែរ ជាមួយចម្លើយដែលជនជាប់ចោទឆ្លើយកន្លងមក និងចម្លើយសាក្សី រួមនឹងភស្តុតាងដែលសមត្ថកិច្ចដកហូតបាន ។ សរុបសេចក្ដីមកតំណាងអយ្យការនៅតែរក្សាបទចោទ និងប្ដឹងសុំតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

## សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទទាំងបីនាក់ បានធ្វើសេចក្ដីសន្និដ្ឋានការពារថា ជនជាប់ចោទបានឆ្លើយសារភាពគ្រប់ដំណាក់កាលនៃនីតិវិធី នេះបង្ហាញឲ្យឃើញថា ជនជាប់ចោទមានភាពស្មោះត្រង់ និងមានការស្ដាយក្រោយចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ។ ជនជាប់ចោទទាំងបីនាក់ជាអនីតិជន ហើយមិនបានរៀនសូត្របន្ថែមទៀត ដូចនេះការពិចារណាមិនបានវែងឆ្ងាយឡើយ ។ ជនជាប់ចោទបច្ចុប្បន្នកំពុងរស់នៅជាមួយអង្គការ រៀនចំនាញដែលពួកគេចូលចិត្ត ជនជាប់ចោទជាក្មេងស្លូតត្រង់មិនដែលបង្កការលំបាកដល់ឪពុកម្ដាយ ។ សរុបសេចក្ដីមកសុំតុលាការប្រកាសទោសព្យួរដល់ជនជាប់ចោទតាមមាត្រា ១០៧ មាត្រា ១០៨ និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ប្រុសតូច បានធ្វើសេចក្ដីសន្និដ្ឋានការពារថា ជនជាប់ចោទរូបនេះជាអនីតិជន ពុំមានការយល់ដឹង ងាយស្រួលអូសទាញពីមិត្តភក្តិ ។ ជនជាប់ចោទឆ្លើយបង្ហាញភាពស្មោះត្រង់ និងមានការស្ដាយក្រោយនៅអ្វីដែលខ្លួនបានធ្វើ ។ ស្នើសុំតុលាការប្រកាលទោសព្យួរដល់ជនជាប់ចោទ ឬអាចប្រកាសទោសបង្វែទៅស្ថាប័ន ឬអង្គការណាមួយ ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] ប្រុសតូច និងឈ្មោះ [redacted] សេរី បានសំណូមពរមកតុលាការថា សុំឲ្យតុលាការជួយបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្តាប់ចម្លើយ និងអំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយ និងអំណានចម្លើយរបស់ជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើភស្តុតាងឯកសារផ្សេងៗក្នុងសំណុំរឿង

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.កាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ វេលាម៉ោង១១ និង៤០ នាទីព្រឹក ឈ្មោះ [redacted] សេរី ឈ្មោះ [redacted] ប្រុសតូច និងឈ្មោះ [redacted] អារុន បានធ្វើសកម្មភាពលូន និងផ្លោះរបងធ្វើពីឥដ្ឋចូលក្នុងដីឡូតិ៍មួយកន្លែងរបស់ឈ្មោះ [redacted] វិចិត្រ ស្ថិតនៅភូមិតាចេក សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប លួចយកដែកបំពង់ទីបមូលប្រវែង ៣ម៉ែត្រ ចំនួនបីដើម ដែកបំពង់ទីបមូលប្រវែង ១,៥ម៉ែត្រ ចំនួនប្រាំដើម ដែកបំពង់ទីបជ្រុងប្រវែង ២ម៉ែត្រ ចំនួនមួយដើម ក្រចាប់ដែកចំនួនដប់ពីរដើម និងសម្ភារៈមួយចំនួនទៀត។ ក្រោយពីជនជាប់ចោទទាំងបីនាក់ ជញ្ជូនសម្ភារៈលួចនេះចេញផុតពីរបង ក៏ត្រូវសមត្ថកិច្ចជិះល្បាតឃើញធ្វើការឃាត់ខ្លួនជនជាប់ចោទទាំងបីនាក់តែម្តង ។

២.ជនជាប់ចោទឈ្មោះ [redacted] សេរី និងឈ្មោះ [redacted] ប្រុសតូច បានឆ្លើយសារភាពនាពេលសវនាការមានភាពស៊ីសង្វាក់គ្នាថា កាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ វេលាព្រឹក ពួកខ្លួនមានគ្នាបីនាក់ គឺឈ្មោះវណ្ណៈ[redacted]ឈ្មោះ[redacted]ប្រុសតូច និងឈ្មោះ [redacted] អារុន បានជិះម៉ូតូមួយគ្រឿងដើរលេងនៅភ្នំក្រោម ។ លុះដល់ម៉ោងប្រហែល ៩ព្រឹក ពួកខ្លួនទាំងបីនាក់ចុះពីភ្នំក្រោមវិញក៏បបួលគ្នាទៅលួចដែកនៅដីឡូតិ៍មួយកន្លែង ស្ថិតនៅភូមិតាចេក សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ។ ពេលដល់ដីឡូតិ៍ពួកខ្លួនខ្លះលូនតាមរបង និងខ្លះទៀតផ្លោះរបងចូលក្នុងដីឡូតិ៍រួចធ្វើសកម្មភាពប្រមូលដែកទីបមូលមួយចំនួន ទីបជ្រុងមួយចំនួន ក្រចាប់ដប់ ពូថៅមួយ ចង្រ្កានហ្គាសមួយ ជញ្ជូនចេញមកក្រៅក៏ឃើញសមត្ថកិច្ចនៅមុខដីឡូតិ៍នោះឃាត់ខ្លួនតែម្តង ។ ចម្លើយសារភាពរបស់ជនជាប់ចោទទាំងពីរនាក់នាពេលសវនាការនេះមានភាពស៊ីសង្វាក់ផងដែរជាមួយចម្លើយដែលជនជាប់ចោទបានសារភាពគ្រប់ដំណាក់កាលនៃនីតិវិធី ដូចនេះ តុលាការជឿថាជនជាប់ចោទទាំងពីរនាក់ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ។

៣.ជនជាប់ចោទឈ្មោះ [redacted] អារុន អវត្តមាននាពេលសវនាការ ។ ប៉ុន្តែតាមចម្លើយរបស់ជនជាប់ចោទរូបនេះឆ្លើយកន្លងមកបានសារភាពថា កាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ វេលាម៉ោង៧ ព្រឹក ខ្លួនឈ្មោះ សេរី ជិះម៉ូតូទៅទារប្រាក់ពីឈ្មោះ ប្រុសតូច ពេលទៅដល់ផ្ទះឈ្មោះ ប្រុសតូច គេថាអត់មានប្រាក់ក៏បបួលគ្នាទៅលួចដែកនៅដីឡូតិ៍មួយកន្លែង ស្ថិតនៅភូមិបុស្សក្រឡាញ់ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប យកទៅលក់កន្លែងអេតចាយបានប្រាក់ ១៥.០០០ (មួយម៉ឺនប្រាំពាន់រៀល) ចែកគ្នា ។

បន្ទាប់មកនាំគ្នាជិះម៉ូតូទៅលេងភ្នំក្រោមមួយសន្ទុះម៉ោងប្រហែល ៩ព្រឹក ពួកខ្លួនក៏បបួលគ្នាទៅលួចដែកនៅដីឡូត៍មួយកន្លែងទៀត ស្ថិតនៅភូមិតាចេក សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ពេលទៅដល់ខ្លួន និងឈ្មោះ សេរី ផ្លោះរបងឈ្មោះ ប្រុសតូច លូនចូល ហើយក៏នាំគ្នាប្រមូលយកដែកបោះតាមរបង និងប្រឡោះទ្វាររួចក៏ចេញមកវិញឃើញសមត្ថកិច្ចនៅមុខដីឡូត៍ និងធ្វើការឃាត់ខ្លួនតែម្តង ។ ចម្លើយសារភាពរបស់ជនជាប់ចោទរូបនេះអាចឲ្យតុលាការជឿបាន ដោយហេតុថា មានភាពស៊ីសង្វាក់នឹងចម្លើយជនជាប់ចោទឈ្មោះ [redacted] ប្រុសតូច និងឈ្មោះ [redacted] សេរី ខាងលើ ។

៤.ចម្លើយសារភាពរបស់ជនជាប់ចោទទាំងបីនាក់ខាងលើនេះ ក៏ស៊ីសង្វាក់នឹងចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វិចិត្រ ថា ខ្លួនមានដីមួយកន្លែងស្ថិតនៅភូមិតាចេក សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ដីនោះធ្វើរបងរៀបឥដ្ឋព័ទ្ធជុំវិញដី និងចាក់សោទ្វារត្រឹមត្រូវ ក្នុងដីឡូត៍មានរោងមួយទំហំ ៤ម៉ែត្រ x ២ម៉ែត្រ ពុំមានជញ្ជាំងទេ ដាក់សម្ភារៈគ្រឿងសំណង់មានដូចជា ដែកទីបមូល ដែកទីបជ្រុង និងសម្ភារៈផ្សេងៗមួយចំនួនទៀត ។ លុះដល់ថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ១១ និង៤០ នាទី ប្រពន្ធខ្លួនបានទូរស័ព្ទមកប្រាប់ខ្លួនថា មានចោរចូលលួចដែកនៅក្នុងដីឡូត៍ខាងលើនេះ ខ្លួនក៏បានជិះម៉ូតូទៅមើលឃើញបាត់សម្ភារៈមានដែកទីបជ្រុងចំនួនបួនដើម ក្រចាប់ប្រហែលចំនួនហាសិបគ្រាប់ និងចង្រ្កានហ្គាសមួយ ក្រៅពីនោះពុំមានបាត់បង់សម្ភារៈអ្វីផ្សេងទៀតទេ ។

៥.តាមកំណត់ហេតុដកហូតវត្ថុតាង ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ របស់នគរបាលរដ្ឋបាលសង្កាត់ជ្រាវ បានដកហូតសម្ភារៈពីឈ្មោះ [redacted] ប្រុសតូច ឈ្មោះ [redacted] សេរី និងឈ្មោះ [redacted] អារុន មាន ដែកទីបមូលប្រាំបីដើម ដែកទីបជ្រុងមួយដើម ចង្រ្កានហ្គាសមួយ ដែកដាប់ប្រាំមួយដើម ពូថៅមួយ ដែកកាយ៉េប្រាំមួយលីបួនដើម ផ្លែស្ទានមួយដើម សោមាត់លេខដប់ប្រាំពីរចំនួនពីរ សោមាត់លេខដប់បីចំនួនមួយ ដែកក្រចាប់ប្រាំមួយ ដែកសម្រាប់ទ្រទឹកភ្លៀងចំនួនបួន ។

៦.ផ្អែកតាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ការដកហូតវត្ថុតាងពីជនជាប់ចោទ និងការឃាត់ខ្លួនជនជាប់ចោទក្នុងបទល្មើសជាក់ស្តែងអាចឲ្យតុលាការជឿ ថា ជនជប់ចោទទាំងបីនាក់ពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់មែន ។

៧.តាមសំបុត្របញ្ជាក់កំណើតលេខ ៣៣១ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០០ របស់ឈ្មោះ [redacted] សេរី ចេញដោយមេចៅសង្កាត់ជ្រាវ គឺឈ្មោះ [redacted] សេរី កើតថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៧ តាមសំបុត្របញ្ជាក់កំណើតលេខ ១០៤ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] អារុន ចេញដោយចៅសង្កាត់ជ្រាវ គឺឈ្មោះ [redacted] អារុន កើតថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ និងតាមសំបុត្របញ្ជាក់កំណើតលេខ ៤៦ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១ ចេញដោយចៅសង្កាត់ជ្រាវ គឺឈ្មោះ [redacted] ប្រុសតូច កើតថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០៧ បើគិតត្រឹមថ្ងៃជនជាប់ចោទទាំងបីនាក់ប្រព្រឹត្តបទល្មើស ថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ គឺឈ្មោះ [redacted] សេរី មានអាយុ ១៤ឆ្នាំ ១១ខែ ២៣ថ្ងៃ ឈ្មោះ [redacted] អារុន មានអាយុ ១៤ឆ្នាំ ១០ខែ ០៤ថ្ងៃ និងឈ្មោះ ទុង ប្រុសតូច មានអាយុ ១៤ឆ្នាំ ០៨ខែ ១៩ថ្ងៃ ដែលជាអនីតិជន មានអាយុលើសពី ១៤ឆ្នាំ ដូចនេះតុលាការអាចប្រកាសទោសព្រហ្មទណ្ឌ លើជនជាប់ចោទបានស្របតាមបញ្ញត្តិមាត្រា ៣៩ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ និងគប្បីប្រកាសទោសលើជនជាប់ចោទស្របតាមបញ្ញត្តិមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

៨.ជនជាប់ចោទទាំងបីនាក់ ជាអនីតិជន មានការយល់ដឹងចំពោះអំពើប្រព្រឹត្តរបស់ខ្លួន ហើយអំពើប្រព្រឹត្តរបស់ជនជាប់ចោទធ្វើឲ្យប៉ះពាល់ដល់សន្តិសុខសង្គម របៀបរៀបរយសាធារណៈ និងធ្វើឲ្យបាត់បង់នូវទ្រព្យសម្បត្តិរបស់ជនរងគ្រោះ ។ ដូចនេះ តុលាការអាចប្រកាសទោសព្រហ្មទណ្ឌលើជនជាប់ចោទរូបនេះបាន ។

៩.អំពើរបស់ជនជាប់ចោទទាំងបីនាក់ ដែលបានដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិរបស់អ្នកដទៃក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដែលអំពើនេះកំណត់ បានជាបទល្មើស លួច ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

១០.មានពិរុទ្ធភាព និងភស្តុតាងដាក់ពន្ធុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ប្រុសតូច ឈ្មោះ [redacted] សេរី និងឈ្មោះ [redacted] អារុន ពីបទ លួច ប្រព្រឹត្តនៅភូមិតាចេក សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

១១.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វិចិត្រ បានដកពាក្យបណ្តឹង ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ មិនប្តឹងទាមទារសំណងការខូចខាត និងសំណងជំងឺចិត្តពីជនជាប់ចោទទាំងបីនាក់ឡើយ ដូចនេះតុលាការពុំលើកយកមកពិចារណាឡើយ ។

១២.តាមបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ឃើញថា ជនជាប់ចោទបានឆ្លើយសារភាពគ្រប់ដំណាក់កាលនៃនីតិវិធីបង្ហាញអំពីស្មារតីភ្ញាក់រលឹក មានការស្តាយក្រោយនៃអំពើប្រព្រឹត្តរបស់ខ្លួន ។ មួយវិញទៀតបើពិនិត្យកាលៈទេសៈនៃបទល្មើស ព្យសនកម្មកើតឡើងតិចតួច ដើមបណ្តឹងរដ្ឋប្បវេណីមិនបានប្តឹងទាមទារសំណងការខូចខាត និងសំណងជំងឺចិត្តឡើយ ហើយជនរងគ្រោះក៏បានទទួលសម្ភារៈដែលបាត់បង់វិញរួចហើយ ។ ជនជាប់ចោទទាំងបីនាក់នេះ ទើបតែប្រព្រឹត្តបទល្មើសលើកទីមួយមិនធ្លាប់មានការផ្តន្ទាទោសពីមុន ។ ចំណុចទាំងនេះ គប្បីតុលាការពិចារណាប្រកាសទោសពន្ធនាគារលើជនជាប់ចោទទាំងបីនាក់ត្រឹមកំរិតអប្បរមា និងគប្បីប្រកាសទោសព្យួរធម្មតាឲ្យជនជាប់ចោទទាំងបីនាក់ផងដែរ ។

## ហេតុដូច្នេះ សម្រេច

**១.ផ្តន្ទាទោស ៖**

ក.ឈ្មោះ [redacted] ប្រុសតូច ភេទប្រុស កើតនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៧ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៣ (បី)ខែ ប៉ុន្តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល ២ (ពីរ)ខែ ២២ (ម្ភៃពីរ)ថ្ងៃ ទោសសល់ពីនេះត្រូវព្យួរ ។

ខ.ឈ្មោះ [redacted] សេរី ភេទប្រុស កើតនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៧ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៣ (បី)ខែ ប៉ុន្តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល ២ (ពីរ)ខែ ២២ (ម្ភៃពីរ)ថ្ងៃ ទោសសល់ពីនេះត្រូវព្យួរ ។

គ.ឈ្មោះ [redacted] អារុន ភេទប្រុស កើតនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០០៧ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៣ (បី)ខែ ប៉ុន្តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល ២ (ពីរ)ខែ ២២ (ម្ភៃពីរ)ថ្ងៃ ទោសសល់ពីនេះត្រូវព្យួរ ។

ពីបទៈ លួច ប្រព្រឹត្តនៅភូមិតាចេក សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី៥ ខែមករា ឆ្នាំ២០២២ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

សាលក្រមនេះជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ [redacted] ប្រុសតូច និងឈ្មោះ [redacted] សេរី និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] អារុន និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វិចិត្រ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃអង្គារ ១០កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥
សៀមរាប ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២
**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**
**ប្រធានក្រុមប្រឹក្សា**

[redacted]

បានថតចម្លងត្រឹមត្រូវចេញពី
ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី
សៀមរាប ថ្ងៃទី២១ ខែ[illegible] ឆ្នាំ២០២២
**ក្រឡាបញ្ជី**

[redacted]